ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**

**អគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស**

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម**

**កម្មវត្ថុ:** របាយការណ៍សន្ទស្សន៍ថ្លៃទំនិញក្នុងស្រុកចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ គិតត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។

**ជូនភ្ជាប់:** -តារាងសន្ទស្សន៍ថ្លៃទំនិញក្នុងស្រុកចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ

តបតាមកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបពីស្ថានភាពថ្លៃទំនិញចាំបាច់មួយចំនួននៅលើទីផ្សាររាជធានី-ខេត្ត ដូចមានជូនភ្ជាប់ក្នុងតារាង។

ខ្ញុំបាទសូមគោរពរាយការណ៍ដោយសង្ខេបអំពីសភាពការណ៍ថ្លៃទំនិញសំខាន់ៗចាំបាច់ប្រចាំជីវភាព គិតត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ធៀបទៅនឹងគ្រាគោល ដូចតទៅ៖

អង្ករផ្ការំដួល កើនឡើង ១.៣៣% អង្ករផ្កាម្លិះ កើនឡើង ១៤.៤៧% អង្ករសែនក្រអូប កើនឡើង ០.៣៣% អង្ករកូនស្រូវ កើនឡើង ១១.៨២% អង្ករបន្លាផ្អៅ កើនឡើង ២០% អង្ករអ៊ីអ៊ែរ ថយចុះ ២២% ស្ករសថៃ កើនឡើង ៧.៣៩% អំបិល ថេរ ត្រីរ៉ស់ កើនឡើង ១៩.២៩% សាច់មាន់ស្រែ កើនឡើង ៦.៣៦% សាច់មានកសិកម្មថយចុះ ០.៧១% សាច់ទា កើនឡើង ១.៣៥% សាច់ជ្រូក កើនឡើង ៩.៧៧% សាច់គោ កើនឡើង ៣.៤៤% ហ្គាស ថយចុះ ១.៤៥% សាំងធម្មតា ថយចុះ ៩.២៨% សាំងស៊ុបពែរ ថយចុះ ៨.២១% ប្រេងម៉ាស៊ូត ថយចុះ ៥.៧១%។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពពីខ្ញុំបាទ ។

ថ្ងៃពុធ ២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

**អគ្គនាយក**